**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីព្យាបាលជាសះស្បើយ ០១នាក់
## និងមិនមានករណីវិជ្ជមានកូវីដ-១៩ ថ្មី នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- **អ្នកព្យាបាលជាសះស្បើយសរុបមានចំនួនកើនឡើងដល់ ១២០នាក់** (ស្មើនឹង ៩៨,៣៦% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់ នៅក្នុងចំនួននេះ មានស្រី ៣៧នាក់ និងបុរស ៨៣នាក់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិចិន ០២នាក់ ស្ត្រីជនជាតិអង់គ្លេស ០៣នាក់ បុរសជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអាមេរិកកាំង ០១នាក់ ស្ត្រីជនជាតិអាមេរិកកាំង ០១នាក់ បុរសជនជាតិបែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ១៩នាក់ (ក្នុងនេះ មានទារកអាយុ ០៩ខែ) ស្ត្រីជនជាតិបារាំង ២១នាក់ បុរសជនជាតិកាណាដា ០២នាក់ បុរសជនជាតិម៉ាឡេស៊ី ១៣នាក់ បុរសជនជាតិឥណ្ឌូនេស៊ី ០២នាក់ ស្ត្រីជនជាតិវៀតណាម ០៣នាក់ បុរសជនជាតិខ្មែរ ៤២នាក់ និងស្ត្រីជនជាតិខ្មែរ ០៧នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។
- **អ្នកដែលកំពុងសម្រាកព្យាបាលសរុបបានថយចុះមកនៅចំនួន ០២នាក់** (ស្ត្រី ០១នាក់ និងបុរស ០១នាក់) កំពុងនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្ត
- **អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់** (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន **១២២នាក់** (ស្ត្រី ៣៨នាក់ និងបុរស ៨៤នាក់)។

**២. ករណីជាសះស្បើយ៖** ចំនួន ០១នាក់

- បុរសជនជាតិខ្មែរ អាយុ ៥៨ឆ្នាំ ស្នាក់នៅក្នុងសណ្ឋាគារមួយនៅក្រុងព្រះសីហនុ (ជាអ្នកប៉ះពាល់ផ្ទាល់ជាមួយក្រុមអ្នកទេសចរបារាំងមានវីរុសកូវីដ-១៩ នៅក្រុងព្រះសីហនុ និង ជាអ្នកគ្រប់គ្រង និង ធ្វើបដិសណ្ឋារកិច្ចផ្ទាល់ជាមួយភ្ញៀវទេសចរបារាំងទាំងអស់នោះ) ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ -១៩ ចំនួន ០២ដង និង ត្រូវបានអនុញ្ញាតអោយចេញពីបន្ទប់ព្យាបាលក្នុងសណ្ឋាគារមួយនៅក្រុងព្រះសីហនុ។

**៣. មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី** នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និង វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និង ស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និង គេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៨ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសៅរ៍ ១០កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩